## II _រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧៣ អនក្រ.បក

### ស្តីពីសៀវភៅស្នាក់នៅ

* * * *

### រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-[illegible]-១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

_តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

### សំរេច

**មាត្រា ១** ._ត្រូវបានបង្កើតសៀវភៅស្នាក់នៅ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២** ._សៀវភៅស្នាក់នៅ ជាសៀវភៅសំរាប់ប្រើប្រាស់ជាវិធានការនគរបាល ដើម្បីស្រង់ពត៌មានអំពីចំនួនមនុស្សដែលស្នាក់នៅក្នុងគេហដ្ឋាននិមួយៗ ។ សៀវភៅនេះ មិនសំរាប់បញ្ជាក់អំពីញាតិភាព ឬ សញ្ជាតិខ្មែរ នៃមនុស្សដែលមានឈ្មោះចុះក្នុងបញ្ជីសៀវភៅនេះឡើយ ។

**មាត្រា ៣** .–ជនគ្រប់រូបដែលជាអ្នកទទួលខុសត្រូវចម្បង នៃគេហដ្ឋាននីមួយៗ ទោះជាជននោះជាម្ចាស់ផ្ទះក្តី ឬ ជាអ្នកជួលក្តី មានកាតព្វកិច្ច ចុះក្នុងសៀវភៅស្នាក់នៅ នូវឈ្មោះមនុស្សគ្រប់រូបដែលរស់នៅជាប់លាប់ជាមួយខ្លួន ។

**មាត្រា ៤** .– ការគ្រប់គ្រង និងការចុះឈ្មោះសៀវភៅស្នាក់នៅ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ

**មាត្រា ៥** .– បែបបទនៃការចុះឈ្មោះ ក្នុងសៀវភៅស្នាក់នៅ ត្រូវកំណត់ដោយប្រកាសដោយក្រសួងមហាផ្ទៃ ។

**មាត្រា ៦** .–អ្នកទទួលខុសត្រូវចម្បងណា ដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមមាត្រា៣ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលយ៉ាងយូរបីខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ត្រូវពិន័យជាប្រាក់ ៥០.០០០រ. ០០ ( ប្រាំម៉ឺនរៀល ) និងតម្រូវអោយជននោះចុះឈ្មោះខ្លួន និងសមាជិកខ្លួនក្នុងសៀវភៅស្នាក់នៅ ចាប់ពីថ្ងៃដែលពិន័យជាប្រាក់ខាងលើនេះ ។

**មាត្រា ៧** .–អាជ្ញាធរមានសមត្ថកិច្ចណា ដែលអនុវត្តភារកិច្ចផ្ទុយពីបទបញ្ញត្តិ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៨** .–បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ , ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ឹង ហួត ហ៊ុន សែន**

******

## ឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្តីពីសៀវភៅស្នាក់នៅ

**ព្រះរាជាណាចក្រកម្ពុជា**

ROYAUME DU CAMBODGE

**ជាតិ សាសនា ព្រះមហាក្សត្រ**

NATION RELIGTION ROI

### សៀវភៅស្នាក់នៅ

CARNET DE RESIDENCE

នាមត្រកូល នាមខ្លួន..............................................................

N OM ET PRENOM

ផ្ទះលេខ ...............ផ្លូវ.........................ក្រុម............................

CHEZ . N° VOIE GROUPE

ភូមិ . មណ្ឌល.......................................................................

VILLAGE

ឃុំ . សង្កាត់........................................................................

COMMUNE QUARTIER

ស្រុក . ខណ្ឌ.........................................................................

DISTRICT

ខេត្ត . ក្រុង..................................... ...........................

PROVINCE . VILLE

ថ្ងៃទី ........... ខែ..........ឆ្នាំ ...........

LE.........................................

.............នគរបាល........................

................POLICE ....................

លេខ...................

N°

ប.ក្បាលទី...........ទំព័រ.........

REGISTRE . N PAGE

«ក» ក្របខាងខាងមុខ